# សារលិខិត
# សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត
# នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
# ក្នុងឱកាស «ទិវាសន្តិភាពអន្តរជាតិ» ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២៣

សូមថ្វាយបង្គំ ព្រះថេរានុថេរៈគ្រប់ព្រះអង្គជាទីសក្ការៈ
បងប្អូនជនរួមជាតិជាទីស្នេហា

ជារៀងរាល់ឆ្នាំ អង្គការសហប្រជាជាតិបានកំណត់យកថ្ងៃទី២១ ខែកញ្ញា ជាថ្ងៃដ៏ពិសេសសម្រាប់បណ្តាប្រទេសនៅទូទាំងសកលលោកប្រារព្ធ«ទិវាសន្តិភាពអន្តរជាតិ» ដើម្បីបង្ហាញនូវការប្តេជ្ញាចិត្តរួមគ្នាលើកតម្លៃសន្តិភាព ក៏ដូចជាការរំលឹកដល់វីរភាពនានាក្នុងការរួមចំណែកធ្វើឱ្យសម្រេចបាននូវសន្តិភាព។ នៅក្នុងឆ្នាំ២០២៣ នេះ ការប្រារព្ធទិវាសន្តិភាពក្រោមមូលបទ «សកម្មភាពដើម្បីសន្តិភាព៖ ការប្តេជ្ញាចិត្តរួមគ្នាសម្រាប់គោលដៅសកល» ដោយផ្តល់គុណតម្លៃជាចម្បងដល់សកម្មភាពដើម្បីសន្តិភាពនឹងអំពាវនាវឱ្យគ្រប់តួអង្គពាក់ព័ន្ធទាំងអស់ ចូលរួមចំណែកធ្វើឱ្យគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពសម្រេចបានជោគជ័យ ដើម្បីបញ្ចប់នូវវិនាសកម្ម ភាពក្រីក្រ ភាពអត់ឃ្លាន ការប្រែប្រួលអាកាសធាតុ និងធានានូវភាពរុងរឿងសម្រាប់ទាំងអស់គ្នា។

ឯកឧត្តម អាន់តូនីញ៉ូ ហ្គូទែរ៉េស អគ្គលេខាធិការអង្គការសហប្រជាជាតិ ធ្លាប់បានលើកឡើងរួចហើយថា «សន្តិភាពនាពេលនេះ គឺជាតម្រូវការដែលមិនអាចខ្វះបានជាងពេលណាៗទាំងអស់។» ដូចនេះ តាងនាមរាជរដ្ឋាភិបាលកម្ពុជា ខ្ញុំ ព្រះករុណាខ្ញុំ សូមសម្តែងអំណរសាទរ និងចូលរួមជាមួយសហគមន៍អន្តរជាតិក្នុងការប្រារព្ធ «ទិវាសន្តិភាពអន្តរជាតិ» ដ៏មហោឡារិកនេះ ដើម្បីលើកកម្ពស់ការយល់ដឹងពីតម្លៃនៃសន្តិភាពដែលមិនអាចកាត់ថ្លៃបាន និងសូមបញ្ជាក់ឡើងវិញនូវឆន្ទៈដ៏មោះមុតរបស់ប្រជាជនកម្ពុជា ក្នុងការការពារនិងចូលរួមកសាងសន្តិភាព ស្ថេរភាព នៅក្នុងប្រទេស តំបន់ និងសកលលោកឱ្យបានគង់វង្សស្ថិតស្ថេរ។

ជនរួមជាតិជាទីស្នេហា

សន្តិភាពមិនមែនជាអ្វីដែលកើតឡើងដោយចៃដន្យនោះទេ។ ដើម្បីកសាងសន្តិភាព យើងទាំងអស់គ្នាត្រូវពុះពារគ្រប់ឧបសគ្គ ប្រកាន់យ៉ាងខ្ជាប់ខ្ជួននូវស្មារតីសាមគ្គីភាព រួបរួមគ្នាជាធ្លុងមួយ និងភាតរភាពជាអន្តរជាតិ។ ភ្នក់ភ្លើងសង្គ្រាម សោកនាដកម្ម ការបែកបាក់រងទុក្ខវេទនាខ្លោចផ្សារកទីបំផុតគ្មាន ដែលប្រជាជាតិយើងបានឆ្លងកាត់ អស់រយៈពេលជាងពីរទសវត្សរ៍កន្លងមក គឺជាមេរៀន និងបទពិសោធន៍ដ៏ជូរចត់ ដែលមិនអាចបំភ្លេចបាន ហើយដែលនាំឱ្យយើងទាំងអស់គ្នាបានយល់យ៉ាងច្បាស់ពីគុណតម្លៃនៃសន្តិភាព។ នៅថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣ ប្រជាជាតិយើងទាំងមូលបានរំដោះខ្លួនទាំងស្រុងចេញពីអាណានិគមបារាំង ក្រោមព្រះរាជបូជនីយកិច្ចដឹកនាំដ៏ក្លៀវក្លារបស់ព្រះមហាវីរក្សត្រខ្មែរ ព្រះបរមរតនកោដ្ឋ ព្រះករុណា ព្រះបាទសម្តេច **នរោត្តម សីហនុ**។ ប៉ុន្តែ ព្រឹត្តិការណ៍ប្រវត្តិសាស្ត្រនេះ បានផ្តល់ពេលវេលាត្រឹមតែជាង ១០ឆ្នាំប៉ុណ្ណោះ ឱ្យប្រជាជនកម្ពុជាបានស្គាល់ និងរស់ក្នុងសុខសន្តិភាព

និងការអភិវឌ្ឍ នៅមុនពេលដែលកម្ពុជាត្រូវធ្លាក់ចូលក្នុងវិនាសកម្មនិងសង្គ្រាមស៊ីវិលជាច្រើនឆ្នាំម្តងទៀត។ ចាប់ពីឆ្នាំ១៩៧០ ដល់ ១៩៧៥ យើងបានឆ្លងកាត់រដ្ឋប្រហារសង្គ្រាមស៊ីវិល អស់រយៈពេល ៥ឆ្នាំ បន្ទាប់មក របបប្រល័យពូជសាសន៍អស់ជាង ៣ឆ្នាំ ហើយបានហែលឆ្លងស្ថានភាពសន្តិភាពខ្លះ និងសង្គ្រាមខ្លះ រយៈពេល ១៨ឆ្នាំបន្ថែមទៀត។

អតីតកាលដ៏លំបាកវេទនារបស់ប្រជាជាតិយើងនេះ ត្រូវបានបិទបញ្ចប់ទាំងស្រុងនៅឆ្នាំ ១៩៩៨ បន្ទាប់ពីបានអនុវត្តយ៉ាងជោគជ័យនូវ **«នយោបាយឈ្នះ-ឈ្នះ»** របស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ដែលបាននាំមកវិញជូនប្រជាជាតិនេះ នូវសន្តិភាពពេញលេញ ឯកភាពជាតិ និងឯកភាពទឹកដីទាំងស្រុង។ ក្នុងរយៈពេល ២៥ឆ្នាំចុងក្រោយនេះ សន្តិភាពបានផ្តល់ឱកាសឱ្យកម្ពុជាផ្លាស់ប្តូរមុខមាត់ថ្មីគួរជាទីមោទនៈបំផុត ក្រោមម្លប់ដ៏ត្រជាក់នៃអង្គព្រះមហាក្សត្រ ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត។

ប្រទេសកម្ពុជាបានក្លាយទៅជាប្រទេសមានសេដ្ឋកិច្ចដែលរីកចំរើនជាង ៧ភាគរយក្នុងមួយឆ្នាំៗ ក្នុងរយៈពេលជាងពីរទសវត្សកន្លងមកនេះ ដែលនាំឱ្យកម្ពុជាសម្រេចបានឋានៈជាប្រទេសមានចំណូលមធ្យមកម្រិតទាប ហើយអាចនឹងឈានទៅសម្រេចបានឋានៈជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ត្រឹមឆ្នាំ២០៣០ និងជាប្រទេសមានចំណូលខ្ពស់ នៅត្រឹមឆ្នាំ២០៥០។ កម្ពុជាដែលពីមុនធ្លាប់តែខ្វះខាត និងត្រូវពឹងផ្អែកស្ទើរទាំងស្រុងទៅលើជំនួយបរទេសដើម្បីអាចរស់រានបាន បច្ចុប្បន្នកម្ពុជាមានមហិច្ឆតាលើកស្ទួយមោទនភាពជាតិ ឱ្យឈានកាន់តែខ្ពស់ឡើង ដូចសម័យអង្គរឡើង តាមរយៈការកសាងជាតិមួយឱ្យរឹងមាំ រស់រវើក រុងរឿង និងមានវិបុលភាព។

ថ្មីៗនេះ កម្ពុជាសម្រេចស្នាដៃធំៗ រួមមាន ការគ្រប់គ្រងការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ដោយជោគជ័យ ការទទួលធ្វើជាប្រធានកិច្ចប្រជុំកំពូលអាស៊ី-អឺរ៉ុបលើកទី ១៣ និងធ្វើជាប្រធានអាស៊ានជាលើកទី៣ ក្នុងប្រវត្តិសាស្ត្រ ដោយបានដឹកនាំកិច្ចប្រជុំកំពូលអាស៊ាន និងកិច្ចប្រជុំកំពូលពាក់ព័ន្ធដោយផ្ទាល់ក្រោយពីវិបត្តិជំងឺកូវីដ-១៩ ព្រមទាំង ជោគជ័យនៃការធ្វើជាម្ចាស់ផ្ទះនៃការប្រកួតកីឡាអាស៊ីអាគ្នេយ៍ លើកទី៣២ និងការប្រកួតកីឡាអាស៊ានប៉ារ៉ាហ្គេម លើកទី១២ និងទស្សនីយភាពមិនអាចប្រកែកបានមួយចំនួនទៀត នៃការរីកចម្រើនប្រកបដោយមោទនភាពរបស់កម្ពុជា។

នាថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៣ កន្លងទៅថ្មីៗនេះ កម្ពុជាបានរៀបចំការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ យ៉ាងរលូន ដែលមានលក្ខណៈសេរី យុត្តិធម៌ ត្រឹមត្រូវ និងមានតម្លាភាព ដោយទទួលបានជោគជ័យយ៉ាងត្រចះត្រចង់។ ប្រជាពលរដ្ឋជាង ៨លាន ២សែននាក់ ត្រូវជាប្រមាណ ៨៤,៥៩% បានចូលរួមបោះឆ្នោត គឺជាសក្ខីកម្មដ៏ប្រចក្សនូវទឹកចិត្តរបស់ប្រជាជាតិកម្ពុជាទាំងមូល ដែលស្រឡាញ់សុខសន្តិភាព និងគោរពគាំទ្រយ៉ាងខ្ជាប់ខ្ជួន នូវគោលការណ៍លទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស និងនីតិរដ្ឋ។

ទន្ទឹមនឹងនេះ នៅក្រោមឆត្ររបស់អង្គការសហប្រជាជាតិ កម្ពុជាបាននិងកំពុងចូលរួមចំណែកយ៉ាងសកម្ម ក្នុងកិច្ចសហប្រតិបត្តិការថែរក្សាសន្តិភាពពិភពលោក។ ចាប់ពីឆ្នាំ២០០៦ មកដល់បច្ចុប្បន្ននេះ កម្ពុជា បានបញ្ជូនកងកម្លាំងសរុបចំនួន ៩,២០៥នាក់ ក្នុងនោះ ស្ត្រី ៧២៨នាក់ ទៅបំពេញបេសកកម្ម ថែរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិក្នុងប្រទេសចំនួន០៩ រួមមាន ប្រទេសឆាដ ស៊ូដង់ ស៊ូដង់ខាងត្បូង អាហ្វ្រិកកណ្តាល លីបង់ ស៊ីប ស៊ីរី ម៉ាលី និងយេម៉ែន។ បច្ចុប្បន្ននេះ កងកម្លាំងកម្ពុជាសរុប ចំនួន ៩០៣នាក់ (ក្នុងនោះស្ត្រី ១៤៧នាក់) កំពុងបំពេញបេសកកម្មថែរក្សាសន្តិភាពនៅប្រទេសស៊ូដង់ខាងត្បូង លីបង់ ម៉ាលី អាហ្វ្រិកកណ្តាល និងយេម៉ែន។

បច្ចុប្បន្ន កម្ពុជាបានបោះជំហ៊ានដ៏ជោគជ័យក្នុងការពង្រឹងសុខុមាលភាពរបស់ប្រជាជន ដោយធានាថា គ្មាននរណាម្នាក់ត្រូវបានបំភ្លេចចោល។ កម្ពុជាប្តេជ្ញាបង្កើនកិច្ចខិតខំទ្វេដងក្នុងការដាក់ចេញ និងអនុវត្តវិធានការ កែទម្រង់នានា ដូចជាការដាក់ឱ្យអនុវត្តនូវយុទ្ធសាស្ត្របញ្ចកោណ ដើម្បីជម្រុញកំណើនសេដ្ឋកិច្ច បង្កើតការងារ ធានាសមធម៌ បង្កើនប្រសិទ្ធភាព និងនិរន្តរភាព សំដៅសម្រេចឱ្យបាន គោលដៅនៃការអភិវឌ្ឍប្រកបដោយចីរភាព នៅឆ្នាំ២០៣០។ កម្ពុជាត្រៀមខ្លួនស្វាគមន៍ និងសហការជាមួយប្រព័ន្ធអង្គការសហប្រជាជាតិ ដៃគូអភិវឌ្ឍន៍ និងភាគីពាក់ព័ន្ធផ្សេងទៀត ដើម្បីសម្រេចកិច្ចការដ៏សំខាន់ទាំងនេះ។

**ជនរួមជាតិជាទីស្នេហា**

រាជរដ្ឋាភិបាលកម្ពុជា នីតិកាលទី៧ នៃរដ្ឋសភា នឹងបន្តតម្កល់ «**សន្តិភាព**» ជាគុណតម្លៃខ្ពស់បំផុត និងប្រកាន់ខ្ជាប់ចំពោះ ពាក្យស្លោក «**អរគុណសន្តិភាព**» របស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**។ ខ្ញុំ ព្រះករុណាខ្ញុំ ជឿជាក់យ៉ាងមុតមាំថា ការប្រារព្ធទិវាសន្តិភាពអន្តរជាតិឆ្នាំនេះ នឹងបន្តបញ្ជាក់ពីការប្តេជ្ញាចិត្តសារជាថ្មីរបស់រាជរដ្ឋាភិបាលកម្ពុជា និងប្រជាជនកម្ពុជា ក្នុងការលើកកម្ពស់តម្លៃសន្តិភាព កិច្ចសហប្រតិបត្តិការ និងការគោរពគ្នាទៅវិញទៅមក។

ជាកិច្ចបញ្ចប់ ខ្ញុំព្រះករុណាខ្ញុំ សូមប្រសិទ្ធពរជូនដល់ជនរួមជាតិជាទីស្នេហា សូមចៀសផុត ពីជំងឺផ្លូវនានា និងសូមប្រកបដោយពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ៕

ថ្ងៃ ចន្ទ ៤កើត ខែភទ្របទ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០២៣

**ហ៊ុន ម៉ាណែត**